## ជំពូក ទី ៩
## អវសានប្បញ្ញត្តិ

មាត្រា ៣៦ .-

អនុក្រឹត្យលេខ ៣២ អនក្រ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ១៩៨៩ ស្តីពីការគ្រប់គ្រង ត្រួតពិនិត្យយានយន្ត និងវិធានរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី និងបទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣៧ .-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីរដ្ឋលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ និងអភិបាលខេត្ត ក្រុងទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួនអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខានិងត្រា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីសុំហត្ថលេខា

រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

ព្រះហស្តលេខា

**នរោត្តម បុប្ផាទេវី**

***

## អនុក្រឹត្យ លេខ ៦៤ អនក្រ.បក
## ស្តីពី
## ប្រតិទិនឈប់សំរាកការងាររបស់មន្ត្រីរាជការ និយោជិត កម្មករ ប្រចាំ ឆ្នាំ ២០០១

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់រយៈពេលបំពេញការងារប្រចាំសប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់គណៈកម្មការអចិន្ត្រៃយ៍ រៀបចំបុណ្យជាតិ-អន្តរជាតិ លេខ ១៦១/២០០០/គ.ប.ជ.អ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០

## សំរេច

**មាត្រា ១ .-** អនុញ្ញាតិអោយមន្ត្រីរាជការ និយោជិត កម្មករ នៃព្រះរាជាណាចក្រកម្ពុជា ទាំងអស់ បានឈប់សំរាកការងារប្រចាំឆ្នាំ ២០០១ តាមប្រតិទិន ដូចខាងក្រោម :

| | | |
|---|---|---|
| -ថ្ងៃទី០១ មករា | - ទិវាចូលឆ្នាំសកល | ឈប់ ០១ថ្ងៃ |
| -ថ្ងៃទី០៧ មករា | - ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | ឈប់ ០១ថ្ងៃ |
| -ថ្ងៃទី០៨ មីនា | - ទិវានារីអន្តរជាតិ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី១៣-១៤-១៥-១៦ មេសា | - ទិវាចូលឆ្នាំប្រពៃណីជាតិ (១) | ឈប់០៤ថ្ងៃ |
| -ថ្ងៃទី០១ ឧសភា | - ទិវាពលកម្មអន្តរជាតិ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី០៧ ឧសភា | - បុណ្យវិសាខបូជា | ឈប់០១ថ្ងៃ |
| -ថ្ងៃទី១១ ឧសភា | - ពិធីបុណ្យច្រត់ព្រះនង្គ័ល | ឈប់០១ថ្ងៃ |
| -ថ្ងៃទី០១ មិថុនា | - ទិវាកុមារអន្តរជាតិ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី១៨ មិថុនា | - ព្រះរាជពិធីបុណ្យចំរើនព្រះជន្មសម្តេចព្រះរាជអគ្គមហេសី នរោត្តម មុនីនាថ សីហនុ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី១៦-១៧-១៨ កញ្ញា | - បុណ្យភ្ជុំបិណ្ឌ | ឈប់០៣ថ្ងៃ |
| -ថ្ងៃទី២៤ កញ្ញា | - ទិវាប្រកាសរដ្ឋធម្មនុញ្ញ និងព្រះរាជពិធីគ្រងរាជសម្បត្តិជាថ្មី របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី២៣ តុលា | - ទិវាសន្និសញ្ញាសន្តិភាពទីក្រុងប៉ារីស | ឈប់០១ថ្ងៃ |
| -ថ្ងៃទី៣០-៣១ តុលា និង ០១ វិច្ឆិកា | - ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ និងពិធីបុណ្យ អុំទូក សំពះព្រះខែ អកអំបុក បណ្តែតប្រទីប (២) | ឈប់០៣ថ្ងៃ |
| -ថ្ងៃទី០៩ វិច្ឆិកា | - ទិវាបុណ្យឯករាជជាតិ | ឈប់០១ថ្ងៃ |
| -ថ្ងៃទី១០ ធ្នូ | - ទិវាសិទ្ធិមនុស្ស អន្តរជាតិ | ឈប់០១ថ្ងៃ |

www.pheakdeylaw.com

មាត្រា ២ .- ពេលវេលាឈប់សំរាកទាំងឡាយណាដែលត្រូវចំថ្ងៃណាមួយ នៃថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ (សៅរ៍ ឬ អាទិត្យ) ត្រូវបានអោយឈប់សំរាកចំនួន ០១ថ្ងៃ នៃថ្ងៃបន្ទាប់ ជាបន្ថែមទៀត ។ ប៉ុន្តែក្នុងករណីត្រូវចំទាំងពីរថ្ងៃជាប់គ្នា គឺទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យនោះ ចំនួនថ្ងៃបន្ទាប់ដែលត្រូវបានអនុញ្ញាតិអោយឈប់បន្ថែមជាជំនួស គឺឈប់តែចំនួន០១ថ្ងៃប៉ុណ្ណោះ ។

មាត្រា ៣ .- បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

បញ្ជាក់ (១) - ទិវាបុណ្យចូលឆ្នាំថ្មី មានរយៈពេល ៤ថ្ងៃ ដោយឆ្នាំនេះ មានវ័នប័តពីរ

(២) - ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ស្របជាមួយពិធីបុណ្យអុំទូក សំពះព្រះខែ អកអំបុក បណ្តែតប្រទីប ។

រាជធានីភ្នំពេញ,ថ្ងៃទី០៥ ខែ កញ្ញា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ៣៣៨ អនក្រ.តត

## ស្តីពី

## ការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

មាត្រា ១ .- ត្រូវបានផ្ទេរលោក កោ ខុនតារា ពីក្រសួងពាណិជ្ជកម្ម អោយទៅបំរើការងារនៅក្របខ័ណ្ឌរដ្ឋបាលស៊ីវិល ក្រសួងមហាផ្ទៃ ។

www.pheakdeylaw.com